**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សុន្ទរកថា
## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
## ក្នុងពិធីប្រគល់ និងប្រកាសផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ២០១២-២០២០

វិមានសន្តិភាព ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២

ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ជាទីមេត្រី!

ថ្ងៃនេះខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយក្រៃលែង ដែលបានចូលរួមជាមួយ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ក្នុងពិធីប្រគល់ និងប្រកាសផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ២០១២-២០២០។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមសម្តែងនូវការកោតសសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំ ប្រឹងប្រែងរបស់ក្រសួងទេសចរណ៍ សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍នេះឡើង។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ២០១២-២០២០ ជាឯកសារជាតិដ៏សំខាន់ ដែលបានបង្ហាញចក្ខុវិស័យច្បាស់លាស់ និងយូរអង្វែងសម្រាប់ការអភិវឌ្ឍទេសចរណ៍កម្ពុជា ប្រកបដោយនិរន្តរភាព ដោយផ្តោតជាសំខាន់ទៅលើសក្តានុពលវប្បធម៌ និងធម្មជាតិ។ ទេសចរណ៍វប្បធម៌ត្រូវបានផ្តល់អាទិភាពខ្ពស់ក្នុងការអភិវឌ្ឍទេសចរណ៍នៅកម្ពុជា ព្រមជាមួយនឹងការធ្វើឲ្យប្រសើរឡើងនូវអេកូទេសចរណ៍ ដែលជាចក្ខុវិស័យ និងគោលដៅទេសចរណ៍ថ្មី រួមចំណែកដល់ការទប់ទល់បម្រែបម្រួលអាកាសធាតុសាកល ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងការរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចបៃតងនៅកម្ពុជា។ ផែនការយុទ្ធសាស្ត្រនេះ បានចង្អុលបង្ហាញថានៅឆ្នាំ២០២០ កម្ពុជានឹងទទួលបានទេសចរអន្តរជាតិប្រមាណ **៧លាននាក់** ព្រមជាមួយនឹងទេសចរក្នុងស្រុកប្រមាណជា **៨ ទៅ ១០លាននាក់**ធ្វើដំណើរទស្សនានៅទូទាំងប្រទេស។ ម្យ៉ាងវិញទៀត ចំណូលទេសចរណ៍ក្នុងវិស័យសេដ្ឋកិច្ចនឹងកើនឡើងដល់ប្រមាណ **៥០០០លានដុល្លា ក្នុងមួយឆ្នាំ** ដែលចំណូលនេះនឹងរួមចំណែកយ៉ាងសំខាន់ដល់កំណើននៃផលិតផលក្នុងស្រុកសរុប ការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងផ្តល់ឱកាសការងារប្រមាណ **៨០ម៉ឺននាក់**ជូនប្រជាពលរដ្ឋ។

ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមគាំទ្រផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ២០១២-២០២០ ដោយហេតុថា វិស័យទេសចរណ៍ដែលមានលក្ខណៈជាប្រព័ន្ធ គឺជាវិស័យអាទិភាពមួយត្រូវបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ជាអន្តរវិស័យរួមចំណែកលើកស្ទួយ និងជំរុញវិស័យដទៃទៀតមានការអភិវឌ្ឍ។

ដើម្បីសម្រេចតាមចក្ខុវិស័យដែលបានកំណត់ នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍នេះ និងធានាដល់ការបែងចែកផលទេសចរណ៍ប្រកបដោយសមធម៌ជូនគ្រប់ផ្នែកពាក់ព័ន្ធទាំងអស់ គោលការណ៍គ្រឹះជាមូលដ្ឋានសំខាន់៥យ៉ាងត្រូវបានដាក់ចេញសម្រាប់ការអនុវត្តៈ

1. ប្រកាន់ជំហរបើកទូលាយក្នុងការធ្វើធុរកិច្ចទេសចរណ៍ ដោយគាំទ្រឲ្យមានការប្រកួតប្រជែងស្មើភាពគ្នាចំពោះមុខច្បាប់ និងប្រកាន់ខ្ជាប់នូវគោលនយោបាយសេដ្ឋកិច្ចទីផ្សារ ដើម្បីបង្កើនបរិយាកាសធុរកិច្ច និងសកម្មភាពទេសចរណ៍នៅកម្ពុជាប្រកបដោយភាពទាក់ទាញ និងភាពកក់ក្តៅ។
2. ជំរុញអនុវត្តយ៉ាងសកម្មនូវគោលនយោបាយគាំទ្រនានា ដល់ការអភិវឌ្ឍទេសចរណ៍ ពិសេសគោលនយោបាយបើកចំហដើងមេឃ ផ្លូវទឹក និងផ្លូវគោក ក្នុងការបង្កើនការសម្រួល ការធ្វើដំណើរ និងដឹកជញ្ជូនទេសចរណ៍ឲ្យកាន់តែមានភាពប្រសើរឡើង។
3. បន្តលើកស្ទួយកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងផ្នែកឯកជន ដៃគូអភិវឌ្ឍន៍ ដើម្បីជំរុញការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជា ការលើកកម្ពស់កិត្យានុភាពជាតិ សាមគ្គីភាព កិច្ចសហប្រតិបត្តិការ និងការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងអន្តរជាតិ។
4. ជំរុញការអភិវឌ្ឍទេសចរណ៍ ដើម្បីរកទីផ្សារលក់ផលិតផលជូនប្រជាពលរដ្ឋ ព្រោះថាវិស័យទេសចរណ៍ គឺជាការនាំចេញនៅនឹងកន្លែង។ ជំរុញលើកទឹកចិត្ត និងបង្កលក្ខណៈងាយស្រួល ព្រមទាំងគាំទ្រឲ្យមានការចូលរួមអភិវឌ្ឍទេសចរណ៍ពីប្រជាពលរដ្ឋ ពិសេសប្រជាពលរដ្ឋនៅមូលដ្ឋាននៅតាមគោលដៅទេសចរណ៍នានា ដើម្បីនិរន្តរភាពនៃការអភិវឌ្ឍផង ការពារ និងផ្តល់ផលប្រយោជន៍ បង្កើតឱកាសការងារ កាត់បន្ថយការធ្វើចំណាកស្រុក និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋផង។
5. លើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ ប្រើប្រាស់មូលដ្ឋានគតិយុត្តនានា ដើម្បីធានាដល់ការការពារផលប្រយោជន៍ទេសចរណ៍ស្របច្បាប់សម្រាប់គ្រប់ភាគីពាក់ព័ន្ធ និងធានាការអភិវឌ្ឍទេសចរណ៍កម្ពុជាប្រកបដោយនិរន្តរភាព គុណភាព និងការទទួលខុសត្រូវ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមផ្តល់អនុសាសន៍មួយចំនួនបន្ថែមទៀតដល់ថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់លំដាប់ថ្នាក់នៃក្រសួងទេសចរណ៍ ក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីជាគន្លឹះក្នុងការចូលរួមចំណែកជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រនេះ និងការអភិវឌ្ឍវិស័យទេសចរណ៍ទាំងមូលដូចខាងក្រោមៈ

1. ត្រូវបន្តខិតខំយកចិត្តទុកដាក់អភិវឌ្ឍផលិតផលទេសចរណ៍ ព្រមទាំងការពង្រឹងគុណភាពផលិតផល និងសេវាកម្មទេសចរណ៍ នៅគ្រប់រាជធានី ខេត្ត ជាពិសេសនៅតំបន់អាទិភាពទេសចរណ៍។ ក្រសួងទេសចរណ៍ត្រូវបន្តយកចិត្តទុកដាក់ សហការ លើការគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ ដោយខិតខំបន្តជំរុញអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងជំរុញការរៀបចំលិខិតបទដ្ឋានគតិយុទ្ធនានាឲ្យបានច្រើនថែមទៀត។ ទន្ទឹមនឹងនេះ

ត្រូវបន្តចលនាប្រឡងប្រណាំង "**ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ**" ដែលជាយុទ្ធនាការ ពង្រឹងគុណភាពផលិតផលទេសចរណ៍ប្រកបដោយប្រសិទ្ធិភាព ភាពស្អាតបៃតង និងត្រូវចូលរួមបំផុសចលនា "**ទេសចរ មួយនាក់ ដើមឈើមួយដើម**" ឬ "**ការដាំដើមឈើផ្តើមចេញពីអ្នក**"។

2. ត្រូវយកចិត្តទុកដាក់ក្នុងការជំរុញបង្កើតសហគមន៍អ្នកលក់វត្ថុអនុស្សាវរីយ៍ និងសមាគមអ្នកលក់វត្ថុអនុស្សាវរីយ៍ ការអភិវឌ្ឍសហគមន៍ទេសចរណ៍ សហគមន៍អេកូទេសចរណ៍ ពិសេសនៅតំបន់ទេសចរណ៍អាទិភាព សំដៅរួមចំណែកការពារ អភិរក្សធនធានធម្មជាតិ សម្បត្តិវប្បធម៌ ប្រពៃណីទំនៀមទំលាប់នៅតាមតំបន់ និងធ្វើឲ្យបងប្អូនប្រជាពលរដ្ឋនៅមូលដ្ឋានមានមុខរបរ មានការងារធ្វើបន្ថែម និងទទួលផលប្រយោជន៍ប្រកបដោយសមធម៌ពីសកម្មភាពទេសចរណ៍ និងសកម្មភាពសេដ្ឋកិច្ចផ្សេងៗទៀត។

3. ត្រូវបន្តយកចិត្តទុកដាក់ បង្កើនកិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន ក្នុងការទាក់ទាញទេសចរមកពីទីផ្សារទេសចរណ៍អាស៊ាន អាស៊ានបូកបី ឥណ្ឌា និងទីផ្សារទើបងើបថ្មី ដូចជាទីផ្សាររុស្ស៊ី អារ៉ាប់ ។ល។ប៉ុន្តែក៏ត្រូវយកចិត្តទុកដាក់រក្សានូវទីផ្សារដែលមានស្រាប់ ដូចជាអឺរ៉ុប និងអាមេរិកផងដែរ។ ត្រូវជំរុញទាក់ទាញទីផ្សារ យុវជន ទីផ្សារ MICE និងទីផ្សារសមស្របផ្សេងទៀតជាមួយផលិតផលកម្ពុជា។ ព្រមជាមួយនេះ ត្រូវបង្កើនយុទ្ធនាការផ្សព្វផ្សាយទេសចរណ៍ "**កម្ពុជា : ព្រះរាជាណាចក្រអច្ឆរិយៈ**" ត្រូវខិតខំធ្វើការផ្សព្វផ្សាយម្ហូបអាហារខ្មែរ និងបង្អែមខ្មែរឲ្យកាន់តែទូលំទូលាយថែមទៀតដល់ភ្ញៀវទេសចរ។ ត្រូវខិតខំជំរុញការរៀបចំក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ ដែលជាយន្តការរកទីផ្សារ និងផ្សព្វផ្សាយ ដ៏មានប្រសិទ្ធភាពសម្រាប់ការអភិវឌ្ឍទេសចរណ៍កម្ពុជា។

4. គណៈកម្មការអន្តរក្រសួង ត្រូវយកចិត្តទុកដាក់ថែមទៀត ក្នុងការសម្រួលការធ្វើដំណើរឲ្យកាន់តែរលូននៅតាមច្រកទ្វារព្រំដែនអន្តរជាតិ និងត្រូវខិតខំរៀបចំហេដ្ឋារចនាសម្ព័ន្ធបដិសណ្ឋារកិច្ចឲ្យកាន់តែប្រសើរឡើងថែមទៀត ដូចជាចំណតរថយន្ត កន្លែងរង់ចាំអាគារអ្នកដំណើរ សេវាប្តូរប្រាក់ សេវាព័ត៌មាន។ល។ ពិសេសការសម្រួលបែប បទធ្វើដំណើរឲ្យបានរហ័ស។ ទន្ទឹមនឹងនេះ ក្រសួងទេសចរណ៍ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ភាគីពាក់ព័ន្ធត្រូវបន្តយកចិត្តទុក ដាក់ក្នុងការសម្របសម្រួល និងទាក់ទាញឲ្យមានការតភ្ជាប់ការហោះហើរឲ្យបានច្រើនថែមទៀតពីអាស៊ាន អាស៊ានបូកបី ឥណ្ឌា រុស្ស៊ី អារ៉ាប់ និងទីផ្សារអឺរ៉ុបមកកម្ពុជា និងជំរុញឲ្យក្រុមហ៊ុនអាកាសចរណ៍ជាតិកម្ពុជាអង្គរអ៊ែរ ពង្រីកជើងហោះហើរ ឲ្យកាន់តែច្រើននៅក្នុងតំបន់ ជាពិសេសតំបន់អាស៊ាន និងអាស៊ានបូកបី។ ព្រមជាមួយនេះ ត្រូវជំរុញយកចិត្តទុកដាក់ទាក់ទាញផងដែរក្រុមហ៊ុនអាកាសចរណ៍ថ្លៃទាប ហោះហើរមកកម្ពុជាកាន់តែច្រើនថែមទៀត និងការធ្វើប្រតិបត្តិការជាលក្ខណៈក្នុងស្រុក។

5. ក្រសួងទេសចរណ៍ ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ពិសេសក្រោមយន្តការគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ និងយន្តការសមស្របនានា ដើម្បីជំរុញការពង្រីកហេដ្ឋារចនាសម្ព័ន្ធគាំទ្រទេសចរណ៍ដូចជា ការស្តារ និងកសាងផ្លូវទៅកាន់

គោលដៅទេសចរណ៍ វាល ឬព្រលានយន្តហោះ ការតភ្ជាប់តាមផ្លូវដែក ការកសាងកំពង់ផែទេសចរណ៍ ការផ្គត់ផ្គង់អគ្គីសនី ទឹកស្អាត និងការគ្រប់គ្រងកាកសំណល់រឹង និងរាវ រួមចំណែកក្នុងចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ"។ នៅក្នុងការអភិវឌ្ឍន៍សម្រាប់រយៈពេលវែង ត្រូវពិនិត្យលទ្ធភាព និងសិក្សាការកសាងព្រលានយន្តហោះកម្រិតអន្តរជាតិថ្មីមួយនៅភ្នំពេញ ដែលមានសមត្ថភាពផ្ទុករហូតដល់ជាង ១០លាននាក់ក្នុងឆ្នាំ។

6. ក្រសួងមហាផ្ទៃ អគ្គស្នងការនគរបាលជាតិ ជាពិសេសអង្គភាពនគរបាលទេសចរណ៍ ត្រូវចូលរួមយ៉ាងសកម្មក្នុងការថែរក្សាសន្តិភាព សុវត្ថិភាព និងសណ្តាប់ ធ្នាប់ជូនភ្ញៀវទេសចរ។ ជាមួយគ្នានេះ ខ្ញុំសូមគាំទ្រដល់ប្រតិបត្តិករ អាជីវករទេសចរណ៍ ក្នុងការចូលរួមបង្កើតឲ្យមានសន្តិសុខសហគ្រាសក្នុងឯកជន ដើម្បីរក្សាសន្តិសុខ សុវត្ថិភាពនៅតាមគោលដៅទេសចរណ៍ទាំងឡាយ ជាជំនួយដល់កម្លាំងសន្តិសុខសាធារណៈ។ ទន្ទឹមនឹងនេះ ក្រសួងទេសចរណ៍ ត្រូវសហការជាមួយក្រសួងមហាផ្ទៃ អគ្គស្នងការនគរបាលជាតិ ក្រសួងសុខាភិបាល វិស័យឯកជន និងស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីពង្រឹងប្រព័ន្ធធានាសុវត្ថិភាពសង្គ្រោះភ្ញៀវទេសចរ ឲ្យបានកាន់តែប្រសើរថែមទៀត ដោយត្រូវរៀបចំឲ្យមានផែនការជាតិធានាសុវត្ថិភាពភ្ញៀវទេសចរ និងត្រូវដាក់ចេញនូវយន្តការ និងវិធានការច្បាស់លាស់នូវសេវាសន្តិសុខ សង្គ្រោះបន្ទាន់ពេលជួបបញ្ហាជាយថាហេតុ។

7. ត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការអភិវឌ្ឍធនធានមនុស្ស ជាពិសេសផ្នែកជំនាញវិជ្ជា ជីវៈទេសចរណ៍ ដោយហេតុថានេះ ជាកត្តាកំណត់ និងជាមូលដ្ឋានក្នុងការពង្រឹងគុណភាពសេវាកម្មទេសចរណ៍។ ជំរុញការកសាងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ និងគ្រឹះស្ថានសិក្សាទេសចរណ៍ជាតិ សម្រាប់អភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍ ដើម្បីធានាដល់ការអនុវត្តកិច្ចព្រមព្រៀងនានា នៅក្នុងតំបន់ និងអន្តរជាតិ ស្តីពីការអភិវឌ្ឍធនធានមនុស្ស និងការធ្វើបំលាស់ទីនៃអ្នកជំនាញទេសចរណ៍ ពិសេសការអនុវត្តក្នុងក្របខណ្ឌអាស៊ាន ចាប់ពីឆ្នាំ២០១៥តទៅ។

8. ស្របពេលដែលយើងខិតខំទាក់ទាញភ្ញៀវទេសចរអន្តរជាតិ ឲ្យមកទស្សនាកម្ពុជា យើងក៏មិនត្រូវភ្លេចពីសារៈសំខាន់ និងចាំបាច់ក្នុងការជំរុញចលនាទេសចរណ៍ក្នុងស្រុក ដើម្បីរួមចំណែកជំរុញសកម្មភាព សេដ្ឋកិច្ចផ្ទៃក្នុង ការលើកកម្ពស់ស្មារតីស្រឡាញ់ជាតិមាតុភូមិ និងចូលរួមក្នុងការ ថែរក្សាធនធានធម្មជាតិ បិតិកភណ្ឌវប្បធម៌ និងជួយដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ពិសេសនៅសហគមន៍មូលដ្ឋាន។

9. ត្រូវខិតខំចាប់យកទស្សនទាន "ស្អាត និងបៃតង" ដែលជាជម្រើសដ៏ឆ្លាតវៃនាពេលបច្ចុប្បន្នសម្រាប់ពេលអនាគត។ ភាពស្អាត ការមានអនាម័យ ការមានរបៀបរៀបរយនៅទីសាធារណៈ ការរក្សានូវភាពបៃតងនៃធម្មជាតិទាំងឡាយរួមទាំង ជីវចំរុះ ការដាំដើមឈើឡើងវិញ ការប្រើប្រាស់ដោយសន្សំសំចៃនៃថាមពលអគ្គីសនី ទឹក ការប្រើប្រាស់ថាមពលកកើតឡើងវិញក្នុងឧស្សាហកម្មទេសចរណ៍ និងនៅគ្រប់ផ្នែកពាក់ព័ន្ធទាំងអស់ និងបង្កើតបាននូវភាពទាក់ទាញយ៉ាងសំខាន់ផង និងជាចលករក្នុងការចូលរួមអភិវឌ្ឍន៍បៃតងផង។

10. យើងមានប្រាសាទអង្គរដ៏ល្បីល្បាញ យើងមានឆ្នេរសមុទ្រដ៏ល្អស្អាត មានតំបន់អេកូទេសចរណ៍ និងទេសចរណ៍ធម្មជាតិដ៏សំបូរបែប ចូរនាំគ្នាថែរក្សា អភិរក្ស និងអភិវឌ្ឍឲ្យបានល្អ។ ទន្ទឹមនឹងនេះ ចូរនាំគ្នា ចូលរួមចលនាធ្វើឲ្យទីក្រុង ទីប្រជុំជន ភូមិឋានរបស់យើងស្អាត មានអនាម័យល្អ គ្មានសំរាម និងថង់ប្លាស្ទិកហើរតាមខ្យល់ ដើម្បីប្រែក្លាយកម្ពុជា ជាគោលដៅទេសចរណ៍បៃតងដ៏ទាក់ទាញមួយក្នុងតំបន់ កម្រិតពិភពលោក។ អ្វីដែលជាប្រយោជន៍បានមកពីវិស័យទេសចរណ៍គឺដើម្បីយើង ក្នុងពេលបច្ចុប្បន្ន និងកូនចៅយើងទៅអនាគត។

11. ត្រូវសិក្សាឲ្យច្បាស់អំពីបញ្ហាប្រឈមនានា ក្នុងការអភិវឌ្ឍទេសចរណ៍ ហើយត្រូវសហការគ្នាដោះស្រាយឲ្យបានសមស្រប និងទាន់ពេលវេលា ដើម្បីដោះរបាំង ឬឧបសគ្គនានា អនុញ្ញាតឲ្យវិស័យទេសចរណ៍អភិវឌ្ឍន៍កាន់តែប្រសើរឡើង។

12. ត្រូវសិក្សា និងវាយតម្លៃជាប្រចាំអំពីប្រសិទ្ធភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ហើយត្រូវខិតខំស្វែងរកប្រភពហិរញ្ញវត្ថុ ដើម្បីការអនុវត្ត។ យន្តការសមស្របមួយចំនួនចាំបាច់ត្រូវបង្កើតឡើង ហើយរចនាសម្ព័ន្ធគ្រប់គ្រងខ្លះ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវពិនិត្យកែសម្រួល ដើម្បីបង្កើនល្បឿននៃការអភិវឌ្ឍទេសចរណ៍កម្ពុជា។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការ និងអ្នកពាក់ព័ន្ធទាំងអស់ ក្នុងនោះរួមមានក្រសួងទេសចរណ៍ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អន្តរក្រសួង ទីស្តីការគណៈរដ្ឋមន្ត្រី ដែលបានសហការគ្នាធ្វើឲ្យផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍នេះ បានចេញជារូបរាងឡើង ហើយក្លាយជាឯកសារដ៏មានតម្លៃបំផុតសម្រាប់ជាតិយើង។ ឆ្លៀតឱកាសនេះ ខ្ញុំសូមអំពាវនាវ គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិក៏ដូចជាប្រជាពលរដ្ឋទាំងមូល សូមគាំទ្រ និងចូលរួមឲ្យបានសកម្មក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ២០១២-២០២០នេះ ឲ្យទទួលបានជោគជ័យ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ភាគីពាក់ព័ន្ធទាំងអស់ ទាំងក្នុងជួររាជរដ្ឋាភិបាល ផ្នែកឯកជន អង្គការជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ នឹងយកផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍នេះទៅប្រើប្រាស់ជាត្រីវិស័យក្នុងការរួមគ្នា ជំរុញកិច្ចអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជាប្រកបដោយនិរន្តរភាព គុណភាព និងការទទួលខុសត្រូវ ដើម្បីជំរុញលើកកម្ពស់ថែមទៀតនូវកិត្យានុភាពកម្ពុជា លើឆាកអន្តរជាតិ និងធ្វើឲ្យកម្ពុជា "**ព្រះរាជាណាចក្រអច្ឆរិយៈ**" ជាគោលដៅទេសចរណ៍ "វប្បធម៌ និងធម្មជាតិ" លំដាប់ពិភពលោក។ ខ្ញុំសូមប្រគល់និងប្រកាសផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ២០១២-២០២០ ឲ្យប្រើប្រាស់ជាផ្លូវការចាប់ពីពេលនេះតទៅ៕